Washington State DEPARTMENT OF SOCIAL & HEALTH SERVICES

កំណត់ជំរាបអំពី សម្មើសុំបញ្ចេញ អាសយដ្ឋាន - ភាគទី 2
NOTIFICATION OF ADDRESS DISCLOSURE REQUEST - PART 2

ផ្ញើក្រដាសដែលបំពេញរួចហើយ ជាមួយនិងដីកាបញ្ជាពីតុលាការ ឬ ឯកសារផ្សេងៗ ទៅការិយាល័យបំរើសហគមន៍ តាមអាសយដ្ឋានខាងក្រោម។

ឈ្មោះអតិថិជន	លេខសំណុំរឿង
ឈ្មោះការិយាល័យ CSO	អាសយដ្ឋាន CSO
ឈ្មោះបុគ្គលិកសម្រួលការខាងបញ្ចេញពត៌មានសាធារណ នៃការិយាល័យ CSO	ទូរសព្ទ

គូសក្នុងប្រអប់ទាំងអស់ដែលត្រូវចំពោះអ្នក

1. ☐ បញ្ចេញអាសយដ្ឋានរបស់ក្មេង។ ខ្ញុំមិនមានដីកាបញ្ជាតុលាការ ដែលដាក់បញ្ញត្តមិនឲ្យបញ្ចេញអាសយដ្ឋានរបស់ក្មេងទៅឲ្យអ្នកស្នើសុំទេ ឬក៏ខ្ញុំនិងមិនទៅសុំដីកាបញ្ជាអ្វីទេ។ ខ្ញុំមិនបាន ឬក៏ខ្ញុំនិងមិនទៅទាក់ទងការិយាល័យ ការពារកុមារ (CPS) ដើម្បីធ្វើសេចក្តីរាយការណ៍ ចោទប្រកាន់អំពី ការរំលោភបំពាន ឬធ្វេសប្រហែសមិនយកចិត្តដាក់លើក្មេង ដោយឪពុក/ម្តាយដែលស្នើសុំអាសយដ្ឋានរបស់ក្មេង។

2. ☐ កុំបញ្ចេញអាសយដ្ឋានរបស់ក្មេង។ មុនបេះវេលា 30 ថ្ងៃ ត្រូវផុតកំណត់ ខ្ញុំនិងផ្តល់ជូន នូវ:

   ☐ ដីកាបញ្ជាពីតុលាការ ដែលដាក់បញ្ញត្តមិនឲ្យបញ្ចេញអាសយដ្ឋានរបស់ក្មេង ទៅឲ្យអ្នកធ្វើសម្មើសុំ; ឬ

   ☐ ខ្ញុំនិងឡើងតុលាការ ដើម្បីសុំដីកាបញ្ជា មិនឲ្យបញ្ចេញអាសយដ្ឋានក្មេង; ឬ

   ☐ ខ្ញុំ និងទាក់ទង ការិយាល័យ CPS ដើម្បីធ្វើសេចក្តីរាយការណ៍ ចោទប្រកាន់អំពី ការរំលោភបំពាន ឬ ធ្វេសប្រហែសមិនយកចិត្តដាក់លើក្មេង ដោយឪពុក/ម្តាយដែលស្នើសុំអាសយដ្ឋានរបស់ក្មេង។

3. ☐ កុំបញ្ចេញ អាសយដ្ឋានរបស់ក្មេង។ ខ្ញុំ:

   ☐ បានដាក់ពាក្យប្តឹង អះអាងនូវមូលហេតុត្រឹមត្រូវ ដោយមិនធ្វើសហការជាមួយ ផ្នែកទាមទារប្រាក់ឧបត្ថម្ភក្មេង; ឬ

   ☐ ខ្ញុំ និង ដាក់ពាក្យប្តឹង អះអាងនូវមូលហេតុត្រឹមត្រូវ ក្នុងរវាង 30 ថ្ងៃ។

4. ☐ កុំបញ្ចេញអាសយដ្ឋានរបស់ក្មេង។ ខ្ញុំកំពុងដាក់សម្មើសុំ ធ្វើសវនាការ ដោយយុត្តិធម៌ ដើម្បីបង្ការមិនឲ្យ DSHS បញ្ចេញពត៌មាននេះទៅឲ្យ ឪពុក/ម្តាយរបស់ក្មេង។ ខ្ញុំយល់ថា សវនាការ មិនអាច បង្ការ DSHS មិនឲ្យបញ្ចេញអាសយដ្ឋានរបស់ក្មេងនេះបានទេ លុះត្រាតែ ចៅក្រមផ្នែករដ្ឋបាល សំរេចថា មាន ល័ក្ខខ័ណ្ឌណាមួយ ឬច្រើនខាងក្រោមនេះ កើតឡើង:

   * មានដីកាបញ្ជាតុលាការ ដែលដាក់បញ្ញត្ត ឬ ដាក់កំរិតនូវសិទ្ធិ របស់ឪពុក/ម្តាយដែលសុំអាសយដ្ឋាននេះ ក្នុងការមកលេងសួរសុខទុក្ខកូន ឬទាក់ទងកូន ឬ ទាក់ទងខ្ញុំ ដោយមានដាក់ប្រការល័ក្ខខ័ណ្ឌ ការពារខ្ញុំ ឬ កូនខ្ញុំ ពីការធ្វើបាបផ្សេងៗ។
   * មានសំណុំរឿងព្យួរទុក នៅតុលាការពាក់ព័ន្ធនិងការរំលោភបំពាន ឬ ធ្វេសប្រហេសមិនយកចិត្តទុកដាក់ចំពោះក្មេង ដោយឪពុក/ម្តាយដែលស្នើសុំអាសយដ្ឋាន។
   * មានការធ្វើសេចក្តីស៊ើបអង្កេតថ្មីៗ ដោយការិយាល័យ ការពារកុមារ (CPS) នូវការចោទប្រកាន់ លើឪពុក/ម្តាយដែលស្នើសុំអាសយដ្ឋាន ថាបានរំលោភបំពាន ឬ ធ្វេសប្រហែសមិនយកចិត្តទុកដាក់លើកូន។

ហត្ថលេខា	ខែថ្ងៃឆ្នាំ

ពត៌មានអំពីសវនាការ ដោយយុត្តិធម៌

បើអ្នកមិនយលព្រមតាមសេចក្តីសំរេចនេះទេ អ្នកប្រហែលជាអាចស្នើសុំធ្វើសវនាការដោយយុត្តិធម៌។ ដើម្បីសុំធ្វើសវនាការ សូមអ្នកទាក់ទងមក ការិយាល័យនេះ ឬក៏សរសេរសំបុត្រ មកការិយាល័យ Office of Appeals, Department of Social and Health Services, P.O. Box 2465, Olympia, WA 98507-2465 ក្នុងរវាង 90 ថ្ងៃចាប់ពីថ្ងៃ ដែលអ្នកបានទទួលសំបុត្រនេះមក។

នៅពេលធ្វើសវនាការអ្នកមានសិទ្ធិធ្វើជាតំណាងខ្លួនឯង តំណាងដោយមេធាវី ឬដោយនរណាម្នាក់ដែលអ្នកសំរេចជ្រើសយកក៏បានដែរ។ អ្នកប្រហែលជាអាចទទួលការឱយឱវាទតាមផ្លូវច្បាប់ ឬ ក៏ការតំណាងដោយឥតគិតថ្លៃ ដោយទាក់ទងមក ការិយាល័យក្រុមវិវាទ។